# បុណ្យគ្រីស្ទម៉ាស់ដ៏ប្លែកមួយ

**ដោយ ជេន ម៉ាកប្រាយដ៍ ឆូត**
ផ្អែកទៅលើដំណើររឿងពិត

*វាមានការលំបាកណាស់ដែលពុំឃើញម៉ាក់ ប៉ុន្តែបុណ្យគ្រីស្ទម៉ាស់នៅតែសប្បាយ ។*

« *ចូរចាំពីទ្រង់ នៅពេលអ្នកស្រមៃពីបុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៥០ ភាសាអង់គ្លេស* ) ។

វាជិតដល់បុណ្យគ្រីស្ទម៉ាស់ហើយ ប៉ុន្តែ ឌីអាហ្គោគ្មានចិត្តរំភើបអ្វីឡើយ ។ នេះគឺជាបុណ្យគ្រីស្ទម៉ាស់ឆ្នាំដំបូង ចាប់តាំងពីឪពុកម្ដាយរបស់គាត់បានលែងលះគ្នាមក ។ ហើយគាត់គ្មានអារម្មណ៍ដូចមុនទេ ។ គាត់ និង ប្អូនប្រុសគាត់សាំយូអែល នឹងមិនឃើញម៉ាក់ទៀតឡើយនៅបុណ្យគ្រីស្ទម៉ាក់នេះ ។

ឌីអាហ្គោបាននិយាយទៅប៉ាថា « អ្វីៗគ្រប់យ៉ាងវាផ្លាស់ប្ដូរហើយ » ។

« ប៉ាដឹង » ។ ប៉ាមានទឹកមុខសោកសៅ ។ « ជួលកាលរឿងរ៉ាវនានាផ្លាស់ប្ដូរមុនវាបានប្រសើរឡើង » ។ គាត់ស្ងាត់មួយសន្ទុះ ហើយបានញញឹម ។ « បុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ *នឹង* ប្លែក ប៉ុន្តែពុំមែនមានន័យថាយើងពុំអាចសប្បាយរីករាយនោះទេ ។ យើងនៅតែអាចប្រារព្ធពិធីប្រសូតរបស់ព្រះអង្គសង្គ្រោះបាន » ។

ឌីអាហ្គោបានងក់ក្បាល ។ វាមានការលំបាកណាស់ដែលពុំឃើញម៉ាក់ ប៉ុន្តែបុណ្យគ្រីស្ទម៉ាស់ *អាច* នៅតែសប្បាយដូចប៉ាទើបបាននិយាយ ។ ឌីអាហ្គោចង់ធ្វើឲ្យបុណ្យគ្រីស្ទម៉ាស់នេះជាគ្រាមួយដ៏រីករាយ ។

គាត់បានទៅបន្ទប់របស់គាត់ដើម្បីគិតពីរឿងនោះ ។ ជួនកាលពេលបុណ្យគ្រីស្ទម៉ាស់ ពួកគេធ្វើការបម្រើជាគ្រួសារ ។ តើឆ្នាំនេះពួកគេនឹងធ្វើអ្វី ?

ឌីអាហ្គោ បានមើលជុំវិញបន្ទប់របស់ខ្លួន ។ គាត់បានឃើញឡានជ័រមួយដែលគាត់ឈប់លេងវា ។ គាត់បានរើសវាឡើង ហើយបង្វិលកង់ឡាននោះ ។ ឡាននោះពុំទាន់ខូចនៅឡើយទេ ។ ប្រហែលជាគាត់ និង ប៉ា ព្រមទាំងសាំយូអែលអាចឲ្យប្រដាប់ប្រដាក្មេងលេងមួយចំនួនទៅក្មេងៗដែលគ្មានប្រដាប់លេងទាំងនោះ !



គាត់បានរកឃើញប្រដាប់ប្រដាក្មេងលេងមួយចំនួនទៀត ហើយដាក់វានៅក្នុងកាបូបជាមួយនឹងឡានជ័រនោះ ។

នៅពេលឌីអាហ្គោបានប្រមូលវាហើយ គាត់បានយកកាបូបនោះទៅបន្ទប់របស់សាំយូអែល ។ គាត់បានសួរថា « តើបងអាចជួយសម្អាតបន្ទប់ប្អូនបានទេ ? វានឹងធ្វើឲ្យប៉ាមានការភ្ញាក់ផ្អើល » ។

សាំយូអែលបានងាកចេញពីរូបភាពដែលគាត់កំពុងគូរ ។ « បាទបាន » ។

ក្មេងប្រុសទាំងពីរបានធ្វើការរួមគ្នាសម្អាតបន្ទប់របស់សាំយូអែល ។ ឌីអាហ្គោបានប្រាប់គាត់អំពីផែនការនោះ ។ ពួកគេបានរកឃើញប្រដាប់ប្រដាក្មេងលេងមួយចំនួន ដែលសាំយូអែលឈប់លេងវា ហើយដាក់វាបន្ថែមចូលទៅក្នុងកាបូប ។



ពេលពួកគេបានសម្អាតចប់ហើយ នោះពួកគេបានយួរកាបូបចុះមកជាន់ក្រោម ។ ឌីអាហ្គោបាននិយាយថា « ប៉ា ពួកកូនមានប្រដាប់ប្រដាក្មេងលេងមួយចំនួន ដែលពួកកូនឈប់លេងវាទៀតហើយ ។ តើពួកកូនអាចឲ្យវាទៅក្មេងៗដែលគ្មានប្រដាប់ប្រដាលេងទាំងនេះបានទេ ? »

ប៉ាបានមើលដោយក្តីរំភើប ហើយរីករាយ ។ « នោះជាយោបល់ល្អណាស់ ! ចូរយើងយកវាទៅមជ្ឈមណ្ឌលដែលមើលថែអ្នកដែលគ្មានផ្ទះនារសៀលនេះ » ។

ការទៅលេងមជ្ឈមណ្ឌលនោះសប្បាយណាស់ ។ ឌីអាហ្គោ និង សាំយូអែលលេងជាមួយក្មេងៗទាំងនោះ ពេលប៉ាបាននិយាយជាមួយមនុស្សពេញវ័យ ។

នៅតាមផ្លូវទៅផ្ទះវិញ ប៉ាបានសួរថាតើមានអ្វីខ្លះទៀតដែលពួកគេអាចធ្វើដើម្បីឲ្យបុណ្យគ្រីស្ទម៉ាស់នេះពិសេសនោះ ។

ឌីអាហ្គោបាននិយាយថា « កាលពីបុណ្យគ្រីស្ទម៉ាស់ឆ្នាំមុនយើងបានធ្វើនំឲ្យអ្នកជិតខាងយើង » ។

ប៉ាបាននិយាយថា « យើងអាចធ្វើវាបាន ។ តោះយើងទៅទិញគ្រឿងមកធ្វើនំយុកឃី » ។

សាំយូអែលបានគិតថា ធ្វើនំយុកឃីជាយោបល់ *ដ៏ល្អ* មួយ ។

កូនប្រុសទាំងពីរនាក់បានជួយប៉ាទិញគ្រឿងផ្សំនៅហាងទំនិញ ។ នៅផ្ទះពួកគេបានលាយម្សៅ ហើយកាត់វាជារាងរូបផ្កាយ និង រូបដើមឈើ ។ ឌីអាហ្គោ និង សាំយូអែលបានដាក់ក្រែមនំយុកឃីជាពណ៌លឿង និង ពណ៌បៃតង ។ ក្រោយមកពួកគេបានយកថង់នំយុកឃីទាំងនោះទៅឲ្យអ្នកជិតខាងរបស់ពួកគេ ។

នៅយប់នោះ ឌីអាហ្គោអស់កម្លាំង ប៉ុន្តែមានចិត្តរីករាយ ។ គាត់ និង សាំយូអែល ព្រមទាំងប៉ាបានធ្វើកិច្ចការល្អៗជាមួយគ្នាជាគ្រួសារ ហើយបានជួយមនុស្សដទៃ ។ ប៉ាមានប្រសាសន៍ត្រូវណាស់ ។ បុណ្យគ្រីស្ទម៉ាស់នេះប្លែកពីមុន ប៉ុន្តែវានៅតែសប្បាយ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ខូឡូរ៉ាដូ ស.រ.អា. ។*



**ការធ្វើជាគំរូ**
ប៉ារបស់ខ្ញុំពុំទៅព្រះវិហារ ប៉ុន្តែខ្ញុំព្យាយាមគោរពបទបញ្ញត្តិនៅពេលខ្ញុំនៅផ្ទះរបស់គាត់តាមរយៈគំរូរបស់ខ្ញុំ អំពីរបៀបដែលខ្ញុំរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។
**ដាស្សែល គី អាយុ ៦ ឆ្នាំ រដ្ឋ ខូឡូរ៉ាដូ ស.រ.អា.**